## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ថ្ងៃ អង្គារ ៤ រោច ខែ ស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

លេខ: ៨០៦៤ កសក

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០២២

**សូមជម្រាបជូន**

**ឯកឧត្តមប្រធានក្រុមហ៊ុន អិល.វ៉ាយ.ភី គ្រុប** (L.Y.P GROUP CO.,LTD)

**កម្មវត្ថុ** ៖ សំណើសុំកំណត់កំពង់ផែ **ក្រុមហ៊ុន អិល.វ៉ាយ.ភី គ្រុប** (L.Y.P GROUP CO.,LTD) ដែលមានទីតាំងនៅភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង សម្រាប់នាវានេសាទ ឬនាវាពាក់ព័ន្ធនឹងការនេសាទបរទេសចូលចត ឡើងផល ផលិតផលជលផល និងប្រើសេវាកំពង់ផែ។

**យោង** ៖ ព្រះរាជក្រមលេខ នស/រកម/០៧១៩/០១០ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាសមាជិកនៃកិច្ចព្រមព្រៀង ស្តីពីវិធានការរដ្ឋម្ចាស់កំពង់ផែ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធានក្រុមហ៊ុន អិល.វ៉ាយ.ភី គ្រុប** (L.Y.P GROUP CO.,LTD) ជ្រាបថា ព្រះរាជាណាចក្រកម្ពុជា បានចូលជាសមាជិកនៃកិច្ចព្រមព្រៀង ស្តីពីវិធានការរដ្ឋម្ចាស់កំពង់ផែ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត (PSMA) របស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ (FAO) នាថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩។ បច្ចុប្បន្នប្រទេសជាសមាជិកមានចំនួន៧២ ក្នុងនោះនៅតំបន់អាស៊ីអាគ្នេយ៍មានចំនួន៦ប្រទេស គឺកម្ពុជា មីយ៉ាន់ម៉ា ឥណ្ឌូនេស៊ី ហ្វីលីពីន ថៃ និងវៀតណាម បានចូលជាសមាជិកអនុវត្តកិច្ចព្រមព្រៀង PSMA។ អនុលោមតាមមាត្រា៧នៃកិច្ចព្រមព្រៀង ភាគីនីមួយៗ ត្រូវកំណត់ និងផ្សព្វផ្សាយអំពីកំពង់ផែ សម្រាប់ឱ្យនាវាបរទេសអាចស្នើសុំចូលចត។ ភាគីនីមួយៗ ត្រូវផ្តល់បញ្ជីឈ្មោះកំពង់ផែដែលបានកំណត់ទៅអង្គការ FAO ដើម្បីផ្សព្វផ្សាយជាសាធារណៈ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទពិនិត្យឃើញថា កំពង់ផែ **ក្រុមហ៊ុន អិល.វ៉ាយ.ភី គ្រុប** (L.Y.P GROUP CO.,LTD) ដែលមានទីតាំងនៅភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង មានលក្ខណៈសមស្របសម្រាប់នាវាបរទេសស្នើសុំចូលចត ឡើងផល ផលិតផលជលផល និងប្រើសេវាកំពង់ផែ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រធានក្រុមហ៊ុន** មេត្តាពិនិត្យ និងអនុញ្ញាតតាមការគួរ។

សូម **ឯកឧត្តមប្រធានក្រុមហ៊ុន** មេត្តាទទួលនូវការគោរពរាប់អានអំពីខ្ញុំ។

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**ចម្លងជូន៖**
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋបាលខេត្តកោះកុង
  "ដើម្បីជូនជ្រាប"
- រដ្ឋបាលជលផល
- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកោះកុង
  "ដើម្បីមុខការ"
- ឯកសារ កាលប្បវត្តិ